ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

# សេចក្តីជូនព័ត៌មាន

## ស្តីពី

## កម្ពុជាស្វាគមន៍ការប្រគល់មកវិញនៃវត្ថុបុរាណខ្មែរ ចំនួន៣រូប ពីសារមន្ទីរជាតិសិល្បៈអាស៊ីនៃវិទ្យាស្ថានស្មិតសូនីញាន

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ មានកិត្តិយសសូមជម្រាបជូនសាធារណជនជ្រាបថា បន្ទាប់ពីធ្វើការចរចាអស់រយៈពេលជាច្រើនឆ្នាំមក រវាងក្រុមការងារកម្ពុជា ជាមួយសារមន្ទីរជាតិសិល្បៈអាស៊ីនៃវិទ្យាស្ថានស្មិតសូនីញាន (National Museum of Asian Art of the Smithsonian Institution) សហរដ្ឋអាមេរិក កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៥ ក្រុមប្រឹក្សានៃវិទ្យាស្ថានស្មិតសូនីញាន បានសម្រេចជាផ្លូវការប្រគល់វត្ថុបុរាណខ្មែរចំនួន៣រូបជូនមកកម្ពុជាវិញ ដែលរួមមាន៖ ព្រះសិរហរិហរៈ ស.វ.ទី១០, ទេពស្រី (ព្រះនាងឧមា?) ដើមស.វ.ទី១០ និងព្រះនាងប្រាជ្ញាបារមី ចុងស.វ.ទី១២។

ការប្រគល់សម្បត្តិវប្បធម៌ដ៏ពិសិដ្ឋទាំង៣រូបនេះ គឺជាលទ្ធផលនៃការស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់ ដោយរកឃើញថា វត្ថុទាំងនេះត្រូវបានលួចនាំចេញដោយខុសច្បាប់ពីកម្ពុជា ក្នុងអំឡុងពេលសង្គ្រាមស៊ីវិល និងអសន្តិសុខ ដែលបង្កឱ្យមានអំពើចោរកម្មរីកសាយនៅក្នុងប្រទេស។ ការបញ្ជូនត្រឡប់មកកម្ពុជាវិញនេះ បញ្ជាក់ពីការប្តេជ្ញាចិត្តនិងមានអត្ថន័យដ៏ជ្រាលជ្រៅ ក្នុងការស្តារឡើងវិញនៃមរតកវប្បធម៌សម្រាប់ប្រជាជនកម្ពុជា។ នេះជាការសម្រេចចិត្តលើកដំបូងបង្អស់សម្រាប់សារមន្ទីរសិល្បៈអាស៊ី ក្នុងការបញ្ជូនសម្បត្តិវប្បធម៌មកប្រទេសដើមវិញ ក្រោមគោលការណ៍នៃក្រមសីលធម៌របស់វិទ្យាស្ថានស្មិតសូនីញាន។

លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈមានប្រសាសន៍ថា "កម្ពុជាតែងបញ្ជាក់ច្បាស់ថា វត្ថុបុរាណខ្មែរដែលបានបញ្ជូនមកមាតុភូមិកំណើតវិញ រួមទាំងវត្ថុទាំង៣នេះ មិនត្រឹមតែជាស្នាដៃសិល្បៈដ៏ពិចិត្រនោះទេ ប៉ុន្តែគឺជានិមិត្តរូបនៃព្រលឹងដូនតា និងអត្តសញ្ញាណជាតិខ្មែរ។ មិនតែប៉ុណ្ណោះ រតនៈសម្បត្តិទាំងនេះ គឺជាឱសថព្យាបាលរបួសផ្លូវចិត្តសម្រាប់ប្រជាជាតិកម្ពុជា ដែលបានឆ្លងកាត់សង្គ្រាមជាច្រើនទសវត្សរ៍កន្លងមក និងការបាត់បង់បេតិកភណ្ឌវប្បធម៌ជាតិ"។

លោកជំទាវបណ្ឌិតសភាចារ្យ ថ្លែងបន្តថា "យើងមានសេចក្តីរំភើបរីករាយចំពោះកិច្ចសហប្រតិបត្តិការជាមួយវិទ្យាស្ថានស្មិតសូនីញាន ក្នុងភាពជាដៃគូប្រកបដោយភាពស្មោះត្រង់ និងជំនឿទុកចិត្តគ្នា ដែលបានបង្កលក្ខណៈល្អប្រសើរដល់ការធ្វើមាតុភូមិនិវត្តន៍នៃសម្បត្តិវប្បធម៌ទាំងនេះ។ យើងក៏សង្ឃឹមយ៉ាងមុតមាំដែរថា សារមន្ទីរដទៃទៀត នឹងយកគម្រូតាមវិទ្យាស្ថានស្មិតសូនីញាន ក្នុងការអនុម័ត និងអនុវត្តគោលការណ៍ក្រមសីលធម៌នេះ ដែលជាគោលការណ៍ផ្តល់ភាពងាយស្រួលសម្រាប់ប្រទេសនានា ដូចជាកម្ពុជា ក្នុងការទាមទារសម្បត្តិវប្បធម៌ដែលបានបាត់បង់ក្នុងសម័យសង្គ្រាម បញ្ជូនត្រឡប់មកប្រទេសកំណើតវិញ"។

លោកជំទាវបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី បានថ្លែងអំណរគុណ និងកោតសរសើរចំពោះការខិតខំប្រឹងប្រែងរបស់សារមន្ទីរជាតិសិល្បៈអាស៊ី និងលោកប្រធាន Chase Robinson ជាពិសេសក្រុមការងារស្រាវជ្រាវ និងអភិរក្ស ដែលបានជួយកិច្ចការនេះឱ្យសម្រេចទៅបាន រួមទាំងស្ថានទូតអាមេរិកនៅភ្នំពេញ និងក្រុមការងាររបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រុមការងារស្រាវជ្រាវជាតិនិងអន្តរជាតិ និងមន្ត្រីសារមន្ទីរដែលបានជួយគាំទ្រ។ ទន្ទឹមនេះ លោកជំទាវបណ្ឌិតសភាចារ្យ ក៏បានថ្លែងអំណរគុណជាពិសេសដល់លោក Bradley J. Gordon នៃក្រុមហ៊ុន Edenbridge Asia ជាទីប្រឹក្សាផ្នែកច្បាប់របស់ក្រសួង និងកញ្ញា Melina Antoniadis នៃ NOTOS Strategies ដែលបានចូលរួមចរចានិងសម្របសម្រួលលើកិច្ចការនេះ។

ថ្ងៃអង្គារ ១១រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៥

| | | |
|---|---|---|
| ១ |  | ឈ្មោះវត្ថុ : ព្រះសិរហរិហរៈ<br>វត្ថុធាតុ : ថ្មភក់<br>កាលបរិច្ឆេទ : សម័យអង្គរ រចនាបថប្រែរូប ស.វ.ទី១០<br>ទំហំ : ២៧.៦ x ១៩.៣ x ១៧.២ស.ម. |
| ២ |  | ឈ្មោះវត្ថុ : ទេពស្រី (ព្រះនាងឧមា?)<br>វត្ថុធាតុ : ថ្មភក់<br>កាលបរិច្ឆេទ : សម័យអង្គរ រចនាបថបាខែង ដើមស.វ.ទី១០<br>ទំហំ : ១២៤.២ x ៣៧.៥ x ២៤.៣ស.ម. |
| ៣ |  | ឈ្មោះវត្ថុ : ព្រះនាងប្រាជ្ញាបារមី<br>វត្ថុធាតុ : សំរិទ្ធ<br>កាលបរិច្ឆេទ : សម័យអង្គរ រចនាបថបាយ័ន្ត ចុងស.វ.ទី១២<br>ទំហំ : ៥២.១ x ២៣.៥ x ១០.២ស.ម. |